# ព្រះវិហារចាស់បាក់បែកក្នុងវត្តរកាអារ

នៅតាមដងទន្លេមេគង្គក្នុងប្រទេសកម្ពុជា គេឃើញមានវត្តអារាមព្រះពុទ្ធសាសនាជាច្រើនបានកសាងឡើងប្រកបដោយក្បាច់រចនា និងការតុបតែងយ៉ាងល្អវិចិត្រ សម្បូរបែបទៅតាមតំបន់ និងសម័យនិយម។ ក្នុងបណ្តាវត្តដ៏ច្រើននោះ វត្តរកាអារក៏បានសាងឡើងប្របដងទន្លេមេគង្គដែរ ស្ថិតនៅត្រើយខាងលិច ក្នុងភូមិសាស្រ្តភូមិរកាអារ ឃុំរកាអារ ស្រុកកងមាស ខេត្តកំពង់ចាម។ វត្តនេះមានព្រះវិហារចាស់បាក់បែកមួយដែលផ្ទុះធ្លាយដំបូល ប្រេះជញ្ជាំង បាក់ខឿន ស្រុតគ្រឹះ និងរលុបគំនូរជាដើម។ ចាប់ពីអំឡុងឆ្នាំ២០១៩មកដល់បច្ចុប្បន្ន ព្រះសង្ឃនិងពុទ្ធបរិស័យចំណុះជើងវត្តរកាអារ បានកសាងព្រះវិហារថ្មីមួយទៀតនៅជាប់នឹងខឿនព្រះវិហារចាស់ (រូបលេខ១)។ ប៉ុន្តែទោះយ៉ាងណាក្តីតាមរយៈសំណេរកត់ត្រាខ្វះៗលើជញ្ជាំងព្រះវិហារ និងស្នាកស្នាមសិល្បៈស្ថាបត្យកម្ម ព្រមទាំងគំនូរក្នុងព្រះវិហារក្នុងព្រះវិហារចាស់ គេអាចស្រមៃទិដ្ឋភាពសង្គមព្រះពុទ្ធសាសនា និងការជ្រោមជ្រែងវត្តអារាមនៃសម័យកសាងព្រះវិហារនេះបានមួយអន្ទើ។



រូបលេខ១ ព្រះវិហារចាស់ និងព្រះវិហារថ្មីស្ថិតក្នុងវត្តរកាអារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# អត្ថបទ៖ ព្រះវិហារចាស់បាក់បែកក្នុងវត្តរកាអារ

ព្រះវិហារចាស់ក្នុងវត្តរកាអារ គឺជាទម្រង់សំណង់ព្រះវិហារជហ្វា៤ ដែលធ្លាប់បានជួសជុលកែលម្អរចនាសម្ព័ន្ធខ្លះកន្លងមក។ បច្ចុប្បន្នព្រះវិហារនេះមានដំបូលប្រក់ក្បឿងស្រកាលេញ ជាដំបូលកិងមានជម្រាលថ្នាក់ៗសងខាង។ នៅលើចុងព្រំដំបូលខាងមុខមានបំពាក់ជហ្វា២ និងជហ្វា២ទៀតនៅចុងព្រំដំបូលខាងក្រោយ ដែលជាចំណុចសម្គាល់ហៅព្រះវិហារជហ្វា៤។[1] ចំណែកនៅចុងចែងដំបូលនីមួយៗមានលម្អដោយនាគដងក្តារ (ឬនាគសន្ទឹក) ជាប្រភេទសិល្បៈចម្លាក់ពុម្ពស៊ីម៉ងត៍។ រីឯនៅផ្នែកបាំងសាចនៃព្រះវិហារមានសសរបេតុងមូលចំនួន២០ដើម ដែលនៅតាមក្បាលសសរនីមួយៗលម្អដោយចម្លាក់គ្រុឌ និងកិន្នរតាមសិល្បៈចម្លាក់ពុម្ពស៊ីម៉ងត៍ដែរ (រូបលេខ២-៣)។ ចំពោះហោជាងទាំងពីរនៃព្រះវិហារនេះ ជាសិល្បៈយ៉ាងសាមញ្ញឆ្លាក់ក្បាច់រចនាពីកំបោរបាយអ ដែលខាងមុខមានរូបទេពប្រណម និងខាងក្រោយមានរូបទៀនមួយដើមតម្កល់លើគម្ពីរត្រង់កណ្តាលសន្ទឹកក្បាច់ (រូបលេខ៣-៥)។ សូមរំលឹកដែរថាបើយោងតាមចំណារលើជញ្ជាំងខាងក្រោយព្រះវិហារបញ្ជាក់ថា សសរបាំងសាច និងពិតានលើបាំងសាច ព្រមទាំងគំនូរលើពិតាននេះសាងឡើងក្នុងឆ្នាំ១៩៩២។ គំនូរលើពិតានបាំងសាចនេះ គូរសាច់រឿងចម្រុះដូចជា រឿងព្រះមហាលក្ខ័យ ព្រះឥន្ទ្រគូរទន្សាយក្នុងវង់ព្រះចន្ទ្រ និងសូម្បីពិធីដង្ហែកេសាកបិលមហាព្រហ្មប្រទក្សិណតាមព្រេងនិទានទាក់ទងនឹងចូលឆ្នាំថ្មីក៏មានគូរបង្ហាញដែរ។ ប៉ុន្តែបើផ្អែកតាមចំណារលើជញ្ជាំងខាងលើ ក៏នាំឲ្យកាត់យល់បានថា ដើមឡើយសសរទាំងអស់នៅខាងក្រៅជញ្ជាំងព្រះវិហារគឺជាសសរឈើ ហើយលើបាំងសាចពុំទាន់មានពិតានឡើយ។





*រូបលេខ២-៣ រចនាសម្ព័ន្ធព្រះវិហារចាស់វត្តរកាអារ*

---

[1] សូមអានបន្ថែម៖ ព្រាប ចាន់ម៉ារ៉ា, ២០១៧: ទំ. ១៣-២៣

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត




រូបលេខ៤-៥ ហោជាងព្រះវិហារចាស់វត្តរកាអារ

ចំពោះរចនាសម្ព័ន្ធសំណង់ផ្នែកខាងក្នុងព្រះវិហារចាស់បាក់បែកសព្វថ្ងៃនេះគឺមានសសរឈើចំនួន៤ជួរ និងមានបល្ល័ង្កព្រះជីវ័ខ្ពស់មួយសាងខាងចុងល្វែង ដែលតាមចំណារបល្ល័ង្កនេះទិបក្សាច់ឡើងវិញក្នុងឆ្នាំ១៩៩២។ ព្រះជីវ័សាងឡើងក្នុងកាយវិការភូមិស្បស៌ (យកព្រះធរណីជាសាក្សី) ដោយមានព្រះហស្តស្តាំដាក់លើព្រះបាទចង្អុលចុះទៅផែនដី។ សោតឯខាងក្រោយបល្ល័ង្កមានឆ្លាក់រូបនាងគង្ហីងព្រះធរណីច្បូតសក់ ដែលស្តែងឲ្យឃើញថាព្រះបដិមាព្រះជីវ័គង់លើបល្ល័ង្ករ័ត្ន ដូចការនិយមក្នុងសិល្បៈអ្នកស្រុកកាន់ពុទ្ធសាសនានៅអាស៊ីទូទៅដែរ (រូបលេខ៦-៧)។[2] ប៉ុន្តែអ្វីដែលគួរឲ្យសង្កេតបន្ថែម គឺនៅលើខឿនបល្ល័ង្កឃើញមានព្រះបដិមាតូចធំបាក់បែកមួយចំនួនតម្កល់នៅខាងមុខព្រះបដិមាព្រះជីវ័ ដែលខ្វះជាបដិមាបុរាណផង។




រូបលេខ៦-៧ ផ្នែកខាងក្នុងព្រះវិហារដែលមានបល្ល័ង្កព្រះជីវ័ខ្ពស់មួយនៅខាងចុងល្វែង

---

[2] សូមអានបន្ថែម៖ "អំពីពាក្យគង្ហីង" ដោយ ហ៊ុន ឈុនតេង ផ្សាយលើគំណា *https://khmercivilization.ams.com.kh/detail/2863* ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំពោះគំនូរខាងក្នុងព្រះវិហារ គេមើលឃើញមានពីរផ្នែកគឺគំនូរពុទ្ធប្រវត្តិមួយផ្នែកគូរជួរខាងលើ និងគំនូររឿងជាតកមួយផ្នែកគូរជួរខាងក្រោមនៃជញ្ជាំងជុំវិញ។ គំនូរទាំងនោះរចនាឡើងដោយវិចិត្រករចំនួន៦រូប ដែលចារឹកឈ្មោះ ដួង សារឿន, ចាប យី, ខេង ស៊ីម, ឌុក ញ៉េប, នៅ គឿន, និង ស៊ុម ប៊ុន។ គំនូរពុទ្ធប្រវត្តិចាប់ផ្ដើមត្រង់ព្រះពោធិសត្វទ្រង់ប្រសូត្រក្រោមដើមសាលព្រឹក្ស គូរនៅលើជញ្ជាំងខាងឆ្វេង រួចបន្តសាច់រឿងតាមលំដាប់ព័ទ្ធទៅខាងក្រោយព្រះជីវ៍គូរត្រង់ព្រះអង្គផ្ចាញ់មារ រហូតមកបញ្ចប់នូវត្រង់ព្រះអង្គយាងចូលនិព្វាន គូរមួយផ្ទាំងធំលើជញ្ជាំងខាងមុខ និងចែកសិរីរិកធាតុ។ ចំណែកឯរឿងជាតកចាប់ផ្ដើមពីរឿងតេមិយ រហូតដល់រឿងមហាវេស្សន្តរ ជាជាតិចុងក្រោយនៃការសន្សំបារមីកាលព្រះសម្មាសម្ពុទ្ធក្នុងជាតិជាព្រះពោធិសត្វ។ លើគំនូរពុទ្ធប្រវត្តិ និងគំនូរជាតកទាំងអស់ ក្រៅពីបង្ហាញខ្លឹមសារតាមសាច់រឿង គេមើលឃើញតម្លៃ ជាវគំនូរនោះហាក់បង្ហាញទិដ្ឋភាពសង្គមសេដ្ឋកិច្ចមួយក្នុងសម័យសង្គមរាស្ត្រនិយម ដ្បិតគំនូររឿងជាតកមួយផ្ទាំងតម្លៃចាប់ពីជាង៥០០០៛ រហូតដល់គំនូររឿងពុទ្ធប្រវត្តិមួយផ្ទាំងតម្លៃក្បែរ២០០០០៛។ ឯអ្នកកើតសទ្ធាសាងគំនូរសោត ខ្លះបរិច្ចាគប្រាក់ចាប់ពី១០០៛ផង (រូបលេខ៨-១០)។



*រូបលេខ៨ គំនូរក្នុងព្រះវិហារគូរត្រង់ "ទ្រង់បរិនិព្វាន"*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត





រូបលេខ៩-១០ គំនូរពុទ្ធប្រវត្តិ និងរឿងជាតកក្នុងព្រះវិហារចាស់វត្តរកាអារ

ដោយឡែក បើសាកល្បងពិនិត្យចំណារផ្សេងៗទៀតនៅលើជញ្ជាំងព្រះវិហារនេះ ជាពិសេសគឺការកត់ត្រានាមពុទ្ធបរិស័ទ ដែលកើតសទ្ធាជ្រះថ្លាចំណាយប្រាក់ និងធនធានសាងព្រះវិហារខាងលើ គេមើលឃើញមានទាំងពុទ្ធបរិស័ទតាមវេនចំណុះជើងវត្ត ពុទ្ធបរិស័ទក្រៅប្រទេសផង និងសូម្បីតែកងកម្លាំងរបស់អង្គការសហប្រជាជាតិក៏បានចូលជាចំណែកកសាងជួសជុលព្រះវិហារនេះផងដែរ។ ទន្ទឹមនឹងនោះ គេឃើញមានប្រាក់ និងសម្ភារៈ (ដែក ស៊ីម៉ង់ត៍ ខ្សាច់...)មួយចំនួនទៀត បានពីការចូលរួមជ្រោមជ្រែងមកវត្ត និងបានពីការរៃអង្គាសទីជិតឆ្ងាយដូចជា វត្តមៀន(អូររាំងឪ), ទួលគោក, ដេអិន, ផ្សារថ្មី (ភ្នំពេញ), ស្រែអំបិល(កោះកុង), អន្លង់គគីរ, វត្តវិហារសំណរ, វត្តព្រែកបង្កង, វត្តខ្ពបលើ (ខេត្តកណ្តាល?), វត្តខ្វ័រ (ព្រៃកលាប), វត្តទូរី, វត្តស្វាយស្រណោះ (កំពង់ចាម) ។ល។







រូបលេខ១១-១៣ ចំណារកត់ត្រាសទ្ធាពុទ្ធបរិស័ទជិតឆ្ងាយចូលកសាងព្រះវិហារចាស់វត្តរកាអារ

សរុបមក ព្រះវិហារចាស់ក្នុងវត្តរកាអារ គឺជាមរតកស្ថាបត្យកម្មពុទ្ធសាសនា ដែលឆ្លុះបញ្ចាំងពីតម្លៃសិល្បៈ កិច្ចខិតខំប្រឹងប្រែងថែរក្សា និងជំនឿសាសនារបស់ពុទ្ធបរិស័ទ ហើយបានឆ្លងកាត់ច្រើនសម័យកាល(ជាពិសេសក្នុងទសវត្សរ៍ឆ្នាំ១៩៦០ និងការជួសជុលឡើងវិញក្នុងឆ្នាំ១៩៩២)។ ទោះបីបច្ចុប្បន្នសំណង់នេះមានសភាពទ្រុឌទ្រោមខ្លាំង រហូត

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មានការសាងសង់ព្រះវិហារថ្មីជំនួសក្តី ប៉ុន្តែស្នាកស្នាមគំនូរ និងចំណារលើជញ្ជាំង នៅតែជាកស្តុតាងប្រវត្តិសាស្ត្រដ៏សំខាន់ ដែលបង្ហាញពីស្ថានភាពសង្គម សេដ្ឋកិច្ច និងសទ្ធាជ្រះថ្លារួមគ្នារបស់សប្បុរសជនទាំងក្នុង និងក្រៅប្រទេស កសាងព្រះវិហារមួយឡើងសម្រាប់គោរពប្រតិបត្តិ។

## ឯកសារយោង


ព្រាប ចាន់ម៉ារ៉ា

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

ហ៊ុន ឈុនតេង

"អំពីពាក្យគង្ហីង" ផ្សាយលើគំ https://khmercivilization.ams.com.kh/detail/2863 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត